តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ របស់មន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្សចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣០៣ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.—**

អនុក្រឹត្យនេះកំណត់អំពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីនគរបាលជាតិកម្ពុជា ដើម្បីធានានិរន្តរភាពការងារ ការគ្រប់គ្រង និងការលើកកម្ពស់សុខុមាលភាពមន្ត្រីនគរបាលជាតិកម្ពុជា ប្រកបដោយប្រសិទ្ធភាព។

**មាត្រា២.—**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.—**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

- ច្បាប់ឈប់ប្រចាំឆ្នាំ សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់មន្ត្រីនគរបាលជាតិកម្ពុជា បន្ទាប់ពីបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា។
- ច្បាប់ឈប់រយៈពេលខ្លី សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើមូលហេតុពិតប្រាកដ ដូចជា ការរៀបអាពាហ៍ពិពាហ៍ ការព្យាបាលជំងឺ ការចូលរួមមរណទុក្ខ ជាដើម។
- ច្បាប់ឈប់សម្រាកលំហែមាតុភាព សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់មន្ត្រីនគរបាលជាតិកម្ពុជាជាស្ត្រី មុននិង/ឬក្រោយពេលសម្រាល។
- ច្បាប់ឈប់សម្រាកព្យាបាលជំងឺ សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលមានជំងឺរ៉ាំរ៉ៃ ត្រូវការរយៈពេលឈប់សម្រាកព្យាបាលតាមវេជ្ជបញ្ជានៃគ្រូពេទ្យមានសមត្ថកិច្ច។
- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលត្រូវការពេលវេលាដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួនឬគ្រួសារ។

## ជំពូកទី២

## ច្បាប់ឈប់ប្រចាំឆ្នាំ

**មាត្រា៤.—**

មន្ត្រីនគរបាលជាតិកម្ពុជាដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ មានសិទ្ធិទទួលបានច្បាប់ឈប់ប្រចាំឆ្នាំ ចំនួន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុង១(មួយ)ឆ្នាំ។

រយៈពេលឈប់នេះ ត្រូវបានកាត់បន្ថយទៅតាមចំនួនសមាមាត្រចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលអនុវត្តច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ឬច្បាប់ឈប់សម្រាកព្យាបាលជំងឺ ឬស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំក្នុងអំឡុងពេលខាងលើ។

មន្ត្រីនគរបាលជាតិកម្ពុជា អាចស្នើសុំច្បាប់ឈប់ប្រចាំឆ្នាំនេះមួយលើកឬច្រើនលើក។

**មាត្រា៥.—**

មន្ត្រីនគរបាលជាតិកម្ពុជាទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពចំណុះក្រសួងមហាផ្ទៃ ត្រូវរៀបចំបញ្ជីផែនការឈប់ប្រចាំឆ្នាំរបស់មន្ត្រីនគរបាលជាតិកម្ពុជាឱ្យបានសមស្រប ដើម្បីធានាឱ្យសកម្មភាពការងារនៃអង្គភាពសាមីប្រព្រឹត្តទៅជាធម្មតា។

## ជំពូកទី៣
## ច្បាប់ឈប់រយៈពេលខ្លី

**មាត្រា៦.-**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងអស់មានសិទ្ធិស្នើសុំច្បាប់ឈប់រយៈពេលខ្លីសរុបចំនួន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុង១(មួយ)ឆ្នាំ។

ក្នុងករណីចាំបាច់ មន្ត្រីនគរបាលជាតិកម្ពុជាអាចទទួលបានការអនុញ្ញាតច្បាប់ឈប់លើសពី១៥(ដប់ប្រាំ)ថ្ងៃ ប៉ុន្តែចំនួនថ្ងៃដែលលើសនោះ ត្រូវយកទៅកាត់ចេញពីចំនួនថ្ងៃនៃច្បាប់ឈប់ប្រចាំឆ្នាំ។

## ជំពូកទី៤
## ច្បាប់ឈប់សម្រាកលំហែមាតុភាព

**មាត្រា៧.-**

មន្ត្រីនគរបាលជាតិកម្ពុជាជាស្ត្រី ត្រូវបានអនុញ្ញាតច្បាប់ឈប់សម្រាកលំហែមាតុភាពរយៈពេល៣(បី)ខែ។ ពាក្យស្នើសុំច្បាប់ឈប់សម្រាកលំហែមាតុភាព ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

## ជំពូកទី៥
## ច្បាប់ឈប់សម្រាកព្យាបាលជំងឺ

**មាត្រា៨.-**

ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវបានអនុញ្ញាតឱ្យមន្ត្រីនគរបាលជាតិកម្ពុជា ពី១(មួយ)ខែទៅ៣(បី)ខែក្នុងមួយលើក បើពិនិត្យឃើញថាមានជំងឺមិនអាចមកបម្រើការងារបាន។ ច្បាប់ឈប់សម្រាកព្យាបាលជំងឺនិងច្បាប់សុំបន្តទៅទៀតអាចអនុញ្ញាតឱ្យបាន លុះត្រាតែមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច ហើយច្បាប់នេះមានរយៈពេលសរុបមិនលើសពី១២(ដប់ពីរ)ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៩.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានច្បាប់ឈប់សម្រាកព្យាបាលជំងឺ រយៈពេល១២(ដប់ពីរ)ខែ ហើយនៅតែពុំអាចមកបម្រើការងារវិញបាន ត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ចលើស្ថានភាពជំងឺ ប្រសិនបើជំងឺនោះនៅតែព្យាបាលមិនជាទៀត មន្ត្រីនគរបាលជាតិកម្ពុជាសាមីត្រូវស្នើសុំដាក់ឱ្យចូលបាត់បង់សមត្ថភាពការងារឬដាក់ឱ្យចូលនិវត្តន៍ តាមលិខិតបទដ្ឋានគតិយុត្តបានកំណត់។

**មាត្រា១០.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលស្ថិតនៅក្រៅក្របខ័ណ្ឌដើមលើសពី៦(ប្រាំមួយ)ខែឡើងទៅ ត្រូវសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺនៅអង្គភាពឬក្រសួង ស្ថាប័ន ដែលខ្លួនកំពុងបំពេញការងារថ្មីនោះ។

ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវបានបដិសេធចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំលើសពី៦(ប្រាំមួយ)ខែឡើងទៅ។

**មាត្រា១១.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលមានជំងឺ ឬគ្រោះថ្នាក់ដោយសារការបំពេញការងារ ឬបំពេញបេសកកម្ម ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច ត្រូវអនុញ្ញាតឱ្យឈប់សម្រាកតាមការកំណត់ដោយទទួលបានបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចពេលកំពុងបំពេញការងារដែរ។

## ជំពូកទី៦

## ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន

**មាត្រា១២.-**

ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវបានអនុញ្ញាតឱ្យមន្ត្រីនគរបាលជាតិកម្ពុជា ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួននិងគ្រួសារ មានរយៈពេលក្នុងមួយលើកយ៉ាងតិច១(មួយ)ខែ រយៈពេលសរុបមិនឱ្យលើសពី៣(បី)ខែឡើយ ក្នុងអំឡុងពេលបម្រើការងារជាមន្ត្រីនគរបាលជាតិកម្ពុជា។

ក្នុងករណីឈប់លើសការកំណត់ខាងលើ មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ។ បើពិនិត្យឃើញថា មន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ពុំអនុវត្តត្រឹមត្រូវដូចការអះអាងនោះ ប្រធានអង្គភាពសាមីឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកោះអញ្ជើញមន្ត្រីនគរបាលជាតិកម្ពុជាឱ្យចូលមកបម្រើការងារវិញជាបន្ទាន់។

## ជំពូកទី៧

## សមាសធាតុនៃច្បាប់ឈប់គ្រប់ប្រភេទ

**មាត្រា១៣.-**

រាល់ពាក្យស្នើសុំច្បាប់ឈប់គ្រប់ប្រភេទ ត្រូវដាក់ជូនប្រធានអង្គភាពឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមឋានានុក្រមនៃមន្ត្រីមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ផ្សេងៗ។

រាល់លិខិតអនុញ្ញាតឱ្យឈប់ ត្រូវចុះកាលបរិច្ឆេទនៃការចាប់ផ្ដើមឈប់និងការចូលបម្រើការងារវិញ ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួងមហាផ្ទៃ។

រាល់ច្បាប់ឈប់គ្រប់ប្រភេទដែលបានអនុញ្ញាតរួចហើយ អង្គភាពសាមីនីមួយៗចំណុះក្រសួងមហាផ្ទៃត្រូវធ្វើការបូកសរុប រួចបញ្ជូនមកអង្គភាពទទួលបន្ទុកគ្រប់គ្រងបុគ្គលិកក្រសួងមហាផ្ទៃ តាមគោលការណ៍កំណត់។

**មាត្រា១៤.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ ត្រូវស្ថិតក្នុងស្ថានភាពផ្ដាច់ចេញពីការងារ រហូតដល់ថ្ងៃចូលបម្រើការងារវិញ។ ក្នុងករណីចាំបាច់ ប្រធានអង្គភាពឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិអញ្ជើញមន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទឱ្យចូលបម្រើការងារវិញ។

**មាត្រា១៥.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានការអនុញ្ញាតច្បាប់ឈប់ប្រចាំឆ្នាំ ច្បាប់ឈប់រយៈពេលខ្លី ច្បាប់ឈប់សម្រាកលំហែមាតុភាព ច្បាប់ឈប់សម្រាកព្យាបាលជំងឺ និងច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវទទួលបានបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចពេលកំពុងបំពេញការងារដែរ។

**មាត្រា១៦.-**

សិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៧.-**

ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវអនុញ្ញាតឱ្យមន្ត្រីនគរបាលជាតិកម្ពុជាចាប់ផ្តើមនិងចេញពីធ្វើការមុន និង/ឬក្រោយម៉ោងកំណត់នៃការងារក្នុង១(មួយ)ថ្ងៃ មិនឱ្យលើសពី១(មួយ)ម៉ោង ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលមានស្ថានភាពដូចខាងក្រោម៖

- មន្ត្រីនគរបាលជាតិកម្ពុជាដែលមានជនចាស់ជរា ឬជនដែលមានស្មារតីវិបល្លាស ឬជនពិការអចិន្ត្រៃយ៍ក្នុងបន្ទុក
- មន្ត្រីនគរបាលជាតិកម្ពុជាដែលមានផ្ទៃពោះ
- មន្ត្រីនគរបាលជាតិកម្ពុជាដែលមានកូនអាយុក្រោម១(មួយ)ឆ្នាំ
- មន្ត្រីនគរបាលជាតិកម្ពុជាដែលមានជំងឺរ៉ាំរ៉ៃ មានការបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច និងមានអាយុចាប់ពី៥០(ហាសិប)ឆ្នាំឡើងទៅ
- មន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលការបណ្តុះបណ្តាលបន្ថែមក្រៅម៉ោងធ្វើការ។

**មាត្រា១៨.-**

ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ពិចារណាឱ្យអស់លទ្ធភាពជាក់ស្តែងរបស់មន្ត្រីនគរបាលជាតិកម្ពុជា ដើម្បីបង្កើនការចូលរួមបំពេញការងារ ការលើកកម្ពស់ផលិតភាពការងាររបស់បុគ្គលនិងអង្គភាព ព្រមទាំងឆ្លើយតបនឹងស្ថានភាព ឬតម្រូវការចាំបាច់ផ្ទាល់ខ្លួន និងគ្រួសាររបស់មន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា១៩.-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលឈប់លើសរយៈពេលនៃការអនុញ្ញាតឱ្យឈប់ ត្រូវទទួលទណ្ឌកម្មខាងវិន័យស្របតាមបទប្បញ្ញត្តិដែលបានកំណត់។ រយៈពេលនៃការឈប់លើសនេះ ត្រូវបានលើកលែងប្រសិនបើបណ្តាលមកពីមានជំងឺ ឬប្រធានសក្តិ ឬគ្រោះថ្នាក់ផ្សេងៗ។ ក្នុងករណីនេះ មន្ត្រីនគរបាលជាតិកម្ពុជាសាមី ត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពឬក្រសួងមហាផ្ទៃ ដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចឬពីគ្រូពេទ្យមានសមត្ថកិច្ច ហើយអាចសុំច្បាប់ឈប់រយៈពេលខ្លីបន្តឬសុំច្បាប់ឈប់ប្រភេទផ្សេងក៏បាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ១៣ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ សីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ